ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥២៨ សហវ.ប្រក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការគ្រប់គ្រងនិងការប្រមូលចំណូលសួយសារធនធានរ៉ែពីការប្រើប្រាស់ធនធានរ៉ែសំណល់ក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងរ៉ែនិងថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ និងព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រាមួយចំនួននៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសអន្តរក្រសួងលេខ ២៨៤ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥ ស្តីពី អត្រាសួយសារលើតម្លៃធនធានរ៉ែ និងនីតិវិធីនៃការបង់ថ្លៃសួយសារ
- បានឃើញប្រកាសរួមលេខ ១២៨ សហវ.ប្រក ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ១៤៥១ សហវ.ប្រក ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- យោងតាមតម្រូវការចាំបាច់នៃការគ្រប់គ្រងធនធានរ៉ែសំណង់

## សម្រេច

**ប្រការ១ .-**

ប្រកាសនេះមានគោលបំណងគ្រប់គ្រងប្រតិបត្តិការធនធានរ៉ែសំណង់ដូចជា ថ្ម ក្រួស ខ្សាច់ ឡាតេរីត អាចម៍ដី ដែលប្រើប្រាស់សម្រាប់ផ្គត់ផ្គង់ឱ្យគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋ និងការប្រមូលចំណូលសួយសារពីការប្រើប្រាស់ធនធានរ៉ែសំណង់ទាំងនេះ ឱ្យប្រព្រឹត្តទៅប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។

**ប្រការ២ .-**

ប្រកាសនេះមានគោលដៅគ្រប់គ្រងប្រតិបត្តិការធនធានរ៉ែសំណង់ដែលប្រើប្រាស់សម្រាប់ផ្គត់ផ្គង់ឱ្យគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋរួមមាន៖

- គ្រប់គ្រងការប្រើប្រាស់ធនធានរ៉ែសំណង់
- សម្រួលនីតិវិធីក្នុងការផ្តល់អាជ្ញាបណ្ណធនធានរ៉ែ និងការលើកលែងកម្រៃសេវាសាធារណៈ
- កំណត់នីតិវិធីក្នុងការប្រមូលចំណូលសួយសារ
- គោលការណ៍អនុវត្តក្នុងករណីលើកលែងសួយសារ។

**ប្រការ៣ .-**

ប្រកាសនេះមានវិសាលភាពគ្របដណ្តប់លើរាល់ប្រតិបត្តិការធនធានរ៉ែសំណង់ដែលប្រើប្រាស់សម្រាប់ផ្គត់ផ្គង់ឱ្យគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចជា គម្រោងសាងសង់ផ្លូវ ស្ពាន ទំនប់ធារាសាស្ត្រ ស្ថានីយវារីអគ្គិសនី និងគម្រោងហេដ្ឋារចនាសម្ព័ន្ធប្រហាក់ប្រហែលដទៃទៀត។

**ប្រការ៤ .-**

អង្គភាពអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋ ទោះជាអង្គភាពរដ្ឋ ឬឯកជនក្តី ដែលយកធនធានរ៉ែសំណង់មកប្រើប្រាស់ដោយផ្ទាល់ក្នុងការសាងសង់ ត្រូវមានអាជ្ញាបណ្ណធនធានរ៉ែ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ និងត្រូវធ្វើការប្រកាសសួយសារនិងបង់ចំណូលសួយសារលើតម្លៃធនធានរ៉ែជូនរដ្ឋ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ៥ .-**

អង្គភាពអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណធនធានរ៉ែស្របតាមគំរូពាក្យស្នើសុំរបស់ក្រសួងរ៉ែនិងថាមពល មកក្រសួងរ៉ែនិងថាមពល ឬមកមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ដែលទីតាំងការដ្ឋានយកធនធានរ៉ែសំណង់នោះស្ថិតនៅ។

ក្រសួងរ៉ែនិងថាមពល ឬមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ត្រូវឆ្លើយតបនឹងសំណើសុំអាជ្ញាបណ្ណធនធានរ៉ែ ក្នុងរយៈពេលយ៉ាងយូរ ៤៥(សែសិបប្រាំ)ថ្ងៃ។ ករណីសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ មិនត្រឹមត្រូវ ឬមិនគ្រប់គ្រាន់ ក្រសួងរ៉ែនិងថាមពល ឬមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ត្រូវបញ្ជាក់តាមរយៈលិខិតឆ្លើយតប។

កម្រៃសេវាសាធារណៈនានា ដែលមានចែងនៅក្នុងប្រកាសរួមលេខ ១២៨ សហវ.ប្រក ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ១៤៥១ សហវ.ប្រក ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពី "ការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល" ត្រូវបានលើកលែង។

**ប្រការ៦ .-**

អង្គភាពអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋ ត្រូវធ្វើការប្រកាសសួយសារនៅអគ្គនាយកដ្ឋានធនធានរ៉ែ នៃក្រសួងរ៉ែនិងថាមពល ឬនៅមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ដែលទីតាំងការដ្ឋានយកធនធានរ៉ែសំណង់នោះស្ថិតនៅ ហើយត្រូវបង់ថ្លៃសួយសារលើតម្លៃធនធានរ៉ែ តាមលិខិតបញ្ជាបង់ប្រាក់ចំណូលលើតម្លៃធនធានរ៉ែដែលចេញដោយអគ្គនាយកដ្ឋានធនធានរ៉ែ នៃក្រសួងរ៉ែនិងថាមពល ឬមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត។

អង្គភាពអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋ ទោះជាធ្វើប្រតិបត្តិការធនធានរ៉ែសំណង់ដោយខ្លួនឯង ឬទិញពីទីផ្សារហើយមានបំណងរួចពីកាតព្វកិច្ចបង់សួយសារ អង្គភាពអនុវត្តគម្រោងនោះត្រូវស្នើសុំទៅរាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្នុងករណីដែលទទួលបានគោលការណ៍ឯកភាពពីរាជរដ្ឋាភិបាល កំណត់ថាកាតព្វកិច្ចបង់សួយសារលើធនធានរ៉ែសំណង់ជាបន្ទុករបស់រដ្ឋ នោះអង្គភាពអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋ នៅតែមានកាតព្វកិច្ចក្នុងការប្រកាសអំពីបរិមាណធនធានរ៉ែសំណង់ទាំងអស់ដែលគ្រោងនឹងប្រើប្រាស់ក្នុងការអនុវត្តគម្រោងតាមគោលការណ៍កំណត់របស់ក្រសួងរ៉ែនិងថាមពល ដើម្បីជាមូលដ្ឋានក្នុងការគណនាសួយសារដែលជាបន្ទុករបស់រដ្ឋ។ បន្ទុកសួយសារត្រូវបញ្ចូលជាចំណែកមួយនៃថវិកាបដិភាគរបស់រាជរដ្ឋាភិបាល ក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋនោះ។

**ប្រការ៧ .-**

ករណីធនធានរ៉ែសំណង់ដែលយកមកប្រើប្រាស់ក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋដែលត្រូវទិញលើទីផ្សារ អង្គភាពអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋត្រូវទិញពីក្រុមហ៊ុន ឬអាជីវករដែលមានអាជ្ញាបណ្ណធនធានរ៉ែត្រឹមត្រូវ។ អង្គភាពនោះត្រូវធ្វើការប្រកាសបរិមាណ និងប្រភពផ្គត់ផ្គង់ធនធានរ៉ែសំណង់ដែលប្រើប្រាស់ក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋ ជូនមកមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ដែលទីតាំងគម្រោងនោះស្ថិតនៅ។

ការប្រកាសអំពីបរិមាណធនធានរ៉ែសំណង់ ត្រូវធ្វើនៅមុនពេលដែលគម្រោងចាប់ផ្តើមអនុវត្ត ដោយត្រូវបញ្ជាក់ពីប្រភពដែលទិញធនធានរ៉ែសំណង់នោះ និងត្រូវរាយការណ៍អំពីបរិមាណធនធានរ៉ែសំណង់ដែលបានប្រើប្រាស់ជាក់ស្តែងរៀងរាល់ ៦(ប្រាំមួយ)ខែម្តង និងនៅពេលបិទបញ្ចប់ការដ្ឋានគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋជាស្ថាពរ។

**ប្រការ៨ .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងរ៉ែនិងថាមពល និងអង្គភាពអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...ខែ...មិគសិរ...ឆ្នាំជូត...ទោស័ក...ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី...២២...ខែ...ធ្នូ...ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត

"ដើម្បីជូនជ្រាប"

- ដូចប្រការ៨ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ